មន្ទីរពេទ្យ
កាល់ម៉ែត
HOPITAL
Calmette

ករុណា ការប្តេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យកាល់ម៉ែត

Calmette's Newsletter N° 09

ខែ មេសា ២០១៩ - មិថុនា ២០១៩

ព្រឹត្តិបត្រលេខ ៩

រៀបចំដោយ
គណៈកម្មការទស្សនាវដ្តីនៃមន្ទីរពេទ្យកាល់ម៉ែត

ដំណឹងផ្សេងៗ

ខែ មេសា ២០១៩ - មិថុនា ២០១៩ ទស្សនាវដ្តីលេខ ៩

PAGE 01 វគ្គបណ្តុះបណ្តាលស្តីពីការវះកាត់ប្រកបដោយសុវត្ថិភាព ឆ្នាំ២០២០ (safe surgery 2020)

PAGE 02 គម្រូគ្រួឧទ្ទេស និងភាពជាអ្នកដឹកនាំគ្រប់កម្រិត...

PAGE 03 DATA C អ្វីជា ជំងឺរលាកត្រពេញប្រូស្តាតស្រួចស្រាវ?

PAGE 04 សូមប្រុងប្រយ័ត្ន ជំងឺខាន់លឿងលើស្បែក និងភ្នែក(Ictère) អាចជាជំងឺមហារីកលំពែងបាន!

PAGE 05 ប្រភេទជំងឺសើស្បែកមួយចំនួននេះអាចកើតលើក្មេងតូចៗ

PAGE 06 កត្តាប្រឈម នៃការធ្លាក់ឈាមក្រោយសម្រាល! "Hémorragie du post-partum"

PAGE 07 របៀបការពារទារកឈ្លក់ទឹកដោះ

PAGE 08 ជំងឺកន្ទុយថ្លែន!

PAGE 09 សំណួរចម្លើយ Quiz ទាក់ទងនឹងសុខភាព

www.facebook.com/calmette.gov.kh hospital@calmette.gov.kh www.calmette.gov.kh

ទក្ដបណ្ដុះបណ្ដាលស្ដីពី “ **ការវះកាត់ប្រកបដោយសុវត្ថិភាព ឆ្នាំ២០២០** (safe surgery 2020)”

នាថ្ងៃព្រហស្បតិ៍ ៩កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៩ មន្ទីរពេទ្យកាល់ម៉ែតមានបើកវគ្គបណ្ដុះស្ដីពី «ការវះកាត់ ប្រកបដោយសុវត្ថិភាពឆ្នាំ២០២០ (safe surgery 2020)» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

វគ្គបណ្ដុះបណ្ដាលនេះផ្ដួចផ្ដើមដោយ មូលនិធិ GE បានសហការគ្នាជាផ្លូវការជាមួយក្រសួងសុខាភិបាលនិងបានអនុវត្តការងារក្រោមការសម្របសម្រួលរបស់ដៃគូដទៃទៀតដូចជា Assist International, ដាល់បឺក(Dalberg), ចា ជាយ ប៉ៅ(JHPIEGO),សាកលវិទ្យាល័យវេជ្ជសាស្ត្រ Harvard និង ជី ហ្វ័រ អាឡាយអិន(G4Alliance)ដើម្បីពង្រឹងប្រព័ន្ធព្យាបាលដោយវះកាត់ឲ្យមានគុណភាព និង សុវត្ថិភាពខ្ពស់ តាមរយៈ ការអភិវឌ្ឍន៍ជំនាញ និងគាំទ្រផ្នែកសម្ភារៈ។

គោលដៅរបស់កម្មវិធី “ការវះកាត់ប្រកបដោយសុវត្ថិភាពឆ្នាំ២០២០” សំដៅកាត់បន្ថយហានិភ័យ ចំពោះអ្នកជំងឺដែលអាចព្យាបាលបានដោយការវះកាត់ និង ពន្លឿនការទទួលបានសេវាវះកាត់ និង ការដាក់ថ្នាំសណ្ដំប្រកបដោយសុវត្ថិភាពនៅទូទាំងប្រទេស។គំនិតផ្ដួចផ្ដើមនេះនឹងផ្ដោតសំខាន់លើការកសាងសមត្ថភាព របស់មន្ទីរពេទ្យកម្ពុជានានា ដើម្បីបន្តអភិវឌ្ឍន៍លើការព្យាបាលដោយវះកាត់ទៅអនាគត។

គម្រោងនេះផ្ដោតជាចម្បងលើមន្ទីរពេទ្យចំនួន៥ រួមមាន មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម មន្ទីរពេទ្យបង្អែកខេត្តតាកែវ និងមន្ទីរពេទ្យបង្អែកជ័យជំនះ ដែលការបណ្ដុះបណ្ដាលមានរយៈពេល១ឆ្នាំ រួមទាំងការតាមដាន និងវាយតម្លៃអំពីប្រសិទ្ធភាព។យើងនឹងធ្វើការចែករំលែកចំណេះដឹងនិងពង្រីកគោលការណ៍នៃការវះកាត់ប្រកបដោយសុវត្ថិភាពនេះទៅបណ្ដាមន្ទីរពេទ្យនានាទូទាំងប្រទេសក្នុងពេលអនាគត។

គម្រូគ្រូឧទ្ទេស និងភាពជាអ្នកដឹកនាំគ្រប់កម្រិត នៃផ្នែកសេវាថែទាំព្យាបាល នៅមន្ទីរពេទ្យសាកលវិទ្យាល័យឈានមុខកម្រិតស្តង់ដារសាកលៈ

តើត្រូវប្រកាន់ឥរិយាបថយ៉ាងដូចម្តេច ចំពោះមុខស្ថានការណ៍ណាមួយដែលកើតឡើងចំពោះយើង តើត្រូវមានចំណេះដឹងអំពីសមត្ថភាពទំនាក់ទំនងអ្វីខ្លះ ដើម្បីឈានសម្រេចបានប្រសិទ្ធភាពខ្ពស់ និងភាពជោគជ័យក្នុងការចូលរួមណែនាំ បង្ហាត់បង្ហាញ ឬផ្តល់ជាភាពគម្រូ ដល់បុគ្គលផ្សេងៗដទៃដែលនៅជុំវិញយើង? ។

គ្រប់សំណួរចោទឡើងខាងលើនិងចំណោទផ្សេងៗទៀតជុំវិញប្រធានបទនៃការផ្លាស់ប្តូរជាវិជ្ជមាននូវឥរិយាបថ និងចំណេះដឹងអំពីសមត្ថភាពទំនាក់ទំនង ត្រូវបានលើកយកមកវែកញែក ពិភាក្សា និងសិក្សាករណីផ្សេងៗ តាមរយៈបទពិសោធន៍ជាក់ស្តែងនៅសហរដ្ឋអមេរិក និងប្រទេសផ្សេងៗទៀតនៅលើពិភពលោក ក្នុងវគ្គបណ្តុះបណ្តាលពិសេសមួយ «EMORY-CALMETTE Mentorship & Communication skills Training Program» ដែលរៀបចំឡើងនៅមន្ទីរពេទ្យកាល់ម៉ែត សម្រាប់រយៈពេលពេញមួយឆ្នាំ ក្នុងឆ្នាំ២០១៩នេះ។

ផ្នែកទីមួយនៃវគ្គបណ្តុះបណ្តាលនេះមានរយៈពេល៤ថ្ងៃ និងបន្តការសិក្សាបណ្តុះបណ្តាលបង្កើនសមត្ថភាព និងវាយតម្លៃចំណេះដឹង និងការអនុវត្តទៀងទាត់រៀងរាល់ខែ តាមរយៈ Online training ពីសហរដ្ឋអាមេរិក។

សមិទ្ធិផលនៃវគ្គបណ្តុះបណ្តាលដែលមានលក្ខណៈដ៏ពិសេសមួយនេះ គឺជាកិច្ចសហការជាដៃគូដ៏ជិតស្និទ្ធរវាងមន្ទីរពេទ្យកាល់ម៉ែតនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យអេម៉ូរី EMORY University នៃរដ្ឋ Georgia ក្រុង Atlanta សហរដ្ឋអាមេរិក។

អ្វីជា ជំងឺរលាកក្រពេញប្រូស្តាតស្រួចស្រាវ ?

ប្រូស្តាត ជាក្រពេញភេទបុរស ស្ថិតនៅផ្នែកខាងក្រោមជាប់នឹងល្លោកនោម ហើយព័ទ្ធជុំវិញបំពង់នោមប្រដាប់ភេទ។ រលាកក្រពេញប្រូស្តាតស្រួចស្រាវជាញឹកញាប់ បណ្តាលពីមេរោគបាក់តេរី ហើយអាចកើតលើមនុស្សប្រុសក្រោយពេញវ័យបន្តពូជ។

ក) មូលហេតុនៃការរលាក៖
- បង្កពីមេរោគនៅផ្លូវភេទ
- បង្កពីមេរោគនៅផ្លូវនោម
- បង្កពីមេរោគនៅក្នុងឈាម



ខ) រោគវិនិច្ឆ័យ៖
- បណ្តុំរោគសញ្ញាគ្រុនក្តៅ
  - ក្តៅខ្លួនលើសពី ៣៨អង្សារសេ
  - រងាញាក់ (Frissons)
  - ឈឺក្បាល
  - ចុករោយដងខ្លួន

- រោគសញ្ញា ផ្លូវនោម
  - នោមក្តៅក្រហាយផ្សា
  - នោមញឹក
  - នោមទាស់
  - ស្ទះនោម

-បច្ចេកទេសលូកគូទនឹងចង្អុលដៃ(Toucherrectal)ទទួលដឹងថាប្រូស្តាតឡើងទំហំតឹង និងមានការឈឺចាប់ខ្លាំង



គ) ការពិនិត្យអមគ្លីនិក ៖
- បន្ទះជ្រលក់ទឹកនោមដើម្បីរកវត្តមានមេរោគ (Bandelette urinaire)
- ការពិនិត្យទឹកនោម (ECBU)
- បណ្តុះមេរោគក្នុងឈាម (Hémoculture)
- ការពិនិត្យឈាមបន្ថែមរកសញ្ញាបង្ករោគ (NFS, CRP)

ឃ) ផលវិបាកភ្លាម។ ៖
- ការរាលដាលនៃមេរោគក្នុងប្រព័ន្ធឈាម (Septicémie à BGN)
- ស្ទះនោម
- កខ្ទុះនៅនឹងក្រពេញប្រូស្តាត (Abrès de la prostate)
- រលាកពងស្វាស (Orchi-épididymite)

ង) ការព្យាបាល
- បំបាត់រោគសញ្ញាផ្លូវនោម
- ព្យាបាលការបង្ករោគ





ច) សន្និដ្ឋានរួម
- ជាប្រភេទជំងឺកើតមានញឹកញាប់
- ងាយស្រួលធ្វើរោគវិនិច្ឆ័យ
- ត្រូវការចាំបាច់ការព្យាបាលទាន់ពេល

"សូមបងប្អូនបុរសៗពេញវ័យមេត្តាមកពិគ្រោះជាមួយក្រុមគ្រូពេទ្យឯកទេសនៅមន្ទីរពេទ្យកាល់ម៉ែត ដើម្បីស្វែងរករោគវិនិច្ឆ័យនៃជំងឺនេះ និងចូលរួមពិភាក្សាអំពីវិធីសាស្ត្រនៃការបង្ការ និងការព្យាបាលឲ្យទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ជៀសវាងបង្កឲ្យគ្រោះថ្នាក់ដល់អាយុជីវិត។

សូមប្រុងប្រយ័ត្ន ជំងឺខាន់លឿងលើស្បែក និងភ្នែក(Ictère) អាចជាជំងឺមហារីកលំពែងបាន!

ក) អ្វីជាមហារីកលំពែង?

មហារីកលំពែង ជាជំងឺកម្រ (rare) តែកាចសាហាវ (agressif) ហើយភាគច្រើនកើតលើមនុស្សប្រុសអាយុចាប់ពី ៤០ឆ្នាំឡើងទៅ។ ៨០%នៃជំងឺនេះភាគច្រើនកើតនៅក្បាលលំពែងជាងខ្លួន និងកន្ទុយលំពែង។



ខ) មូលហេតុ និងកត្តារួមផ្សំ (Causes et facteur de risque)

គេនៅមិនទាន់រកឃើញអំពីមូលហេតុពិតប្រាកដនៃជំងឺមហារីកលំពែងនេះនៅឡើយទេប៉ុន្តែមានកត្តារួមផ្សំមួយចំនួនដែលអាចបង្កឲ្យមានជំងឺមហារីកនេះ ៖

- ទឹកនោមផ្អែម
- រលាកលំពែងរ៉ាំរ៉ៃ
- ស្រា និងបារី
- អាហារសំបូរទៅដោយខ្លាញ់ និងសាច់សត្វ
- និងកត្តាតំណពូជផ្សេងៗទៀត

គ) រោគសញ្ញា

-គេពិបាកនឹងឃើញរោគសញ្ញាជាក់លាក់ណាស់វាកើតឡើងដោយស្ងៀមស្ងាត់ហើយអ្នកជំងឺអាចឈឺនៅចុងដង្ហើម ដែលធ្វើឲ្យអ្នកជំងឺមិនសូវឃ្លាន ឬថយចំណង់អាហារ។

- អាចរាកមួល
- មានទឹកនោមផ្អែម
- ឡើងលឿង នៅលើស្បែក និងភ្នែក
- ស្រកទម្ងន់





ឃ) ការព្យាបាល

ការព្យាបាលគឺអាស្រ័យទៅលើទីតាំងរបស់ដុំមហារីក ដោយពឹងផ្អែកទៅលើវិធីវះកាត់។ គ្រូពេទ្យវះកាត់ នឹងកាត់យកបំណែកណាមួយនៃលំពែងដែលមានដុំមហារីក។ក្រោយវះកាត់រួចអ្នកជំងឺអាចត្រូវព្យាបាលបន្ថែមដោយថ្នាំគីមីឬបាញ់កាំរស្មី។

«សូមលោក លោកស្រីមកទទួលប្រឹក្សាជាមួយក្រុមការងារវេជ្ជបណ្ឌិតឯកទេសជំនាញមហារីក វះកាត់មហារីកនៃមន្ទីរពេទ្យកាល់ម៉ែត អំពីវិធីសាស្ត្រព្យាបាលជំងឺមហារីក ឲ្យបានទាន់ពេល និងទទួលបានប្រសិទ្ធភាពខ្ពស់។»

ប្រភេទជំងឺសើស្បែកមួយចំនួននេះ អាចកើតលើក្មេងតូច។!

យើងតែងតែរំពឹងថា ស្បែកកូនក្មេងជាស្បែកផូរផង់រលោងម៉ដ្ឋ ប៉ុន្តែជាញឹកញាប់ក្មេងងាយប្រឈមនឹងបញ្ហាស្បែកដូចមនុស្សធំដែរ ដោយសារស្បែកគឺជាសរីរាង្គដែលប្រឈមដោយផ្ទាល់ជាមួយបរិស្ថាន។ ជំងឺស្បែកមួយចំនួនធំដែលកើតលើក្មេងតូចតែស្រួចស្រាល ហើយជារឿយៗ អាចជាសះស្បើយដោយខ្លួនឯងដោយមិនបន្សល់ទុកនូវស្លាកស្នាមអ្វីទាំងអស់។សូមងាកមកស្វែងយល់ពីជំងឺស្បែកមួយចំនួនដែលកើតលើក្មេងតូច ដូចខាងក្រោមនេះ៖

១. Vernix caseosa: កម្អែលខ្លាញ់ស្អិតពណ៌ស ឬ ពណ៌ប្រផេះ អាចមាននៅលើស្បែកក្មេងដែលទើបកើតដែលមានតួនាទីចូលរួមការពារទារកប្រឈមនឹងបរិស្ថានជុំវិញ។ ស្ថានភាពស្បែកនេះនឹងរលាយមករកភាពធម្មតាដោយខ្លួនឯង។

២. Sebaceous hyperplasia: ការរីកត្រដែតនៃក្រពេញខ្លាញ់នៅលើ ច្រមុះ ថ្ពាល់ ពុកមាត់ និងថ្ងាសគេសង្កេតឃើញភាគច្រើននៅលើក្មេងដែលកើតគ្រប់ខែ កើតឡើងដោយសារឥទ្ធិពលអរម៉ូន androgen ពីម្តាយ។ ស្ថានភាពនេះនឹងបាត់ទៅវិញដោយឯកឯង។

៣. Milium (plural Milia): កន្ទួលតូចៗពណ៌ស រឹង នៅលើមុខ ខ្លួន ដៃជើង ប្រដាប់ភេទ និងក្នុងមាត់ អាចមាននៅលើស្បែកក្មេងដែលទើបកើត ហើយអាចបាត់ទៅវិញដោយឯកឯង ឬករណីខ្លះត្រូវឆ្កឹះយកចេញដោយបច្ចេកវិជ្ជាពេទ្យ។

៤.Miliaria: កន្ទួលពងទឹកតូចៗថ្លា ឬក្រហមឈូកលាយជាមួយខ្ទុះបណ្តាលមកពីសីតុណ្ហភាពក្តៅ នាំឲ្យកកស្ទះរន្ធញើស។ ករណីនេះសង្កេតឃើញនៅថ្ងាស ក ខ្លួន និងកន្លែងហប់។ ស្ថានភាពនេះអាចបាត់ទៅវិញដោយស្ងៀកសំលៀកបំពាក់ត្រជាក់ និងបន្ថយសីតុណ្ហភាពកន្លែងរស់នៅឲ្យត្រជាក់ល្មម។

៥.Toxicerythemaofnewborn: ស្ថានភាពនេះកើតឡើងលើក្មេងតូចដែលកើតអត់គ្រប់ខែ ឬទម្ងន់តិចជាង ២៥០០ក្រាម។ ស្តែងឡើងជា កន្ទួលស្បែកក្រហម អាចលាយឡំជាមួយកន្ទួលខ្ទុះពណ៌លឿងនៅ មុខ ខ្លួន ដៃជើង លើកលែងបាតដៃបាតជើង។ ជំងឺនេះកើតឡើងដោយមូលហេតុមិនច្បាស់លាស់ ហើយកើតនៅថ្ងៃទី២នៃថ្ងៃចាប់កំណើត និងបាត់ទៅវិញបន្ទាប់ពី១ទៅ៤សប្តាហ៍។

៦.Pityriasisalba: ភាគច្រើនកើតលើក្មេងតូចដែលមានជំងឺatopicdermatis ស្តែងចេញជាបន្ទះសជាមួយក្រមរស្តើង ភាគច្រើនសង្កេតឃើញនៅមុខជាពិសេសថ្ពាល់។ជំងឺនេះអាចជាដោយមិនបាច់ព្យាបាលឬជៀសវាងបានដោយជៀសកម្តៅថ្ងៃ។ បើករណីធ្ងន់គួរប្រើប្រាស់ moisturizing cream និង topical steroid ដែលអាចសម្រាលរោគសញ្ញាបាន។

៧. Molluscum contagiosum: បង្កដោយ poxvirus (molluscum contagiosum virus) សង្កេតឃើញកើតលើក្មេងក្រោមអាយុ១០ឆ្នាំ រស់នៅតំបន់អាកាសធាតុក្តៅ ហើយឆ្លងតាមរយៈការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការប្រើប្រាស់សម្ភារៈរួម។ ជាកន្ទួលរឹងមានចំណុចផតកណ្តាល ពណ៌ដូចស្បែក ឬក្រហមឈូក។ ព្យាបាលដោយ curettage តាមបច្ចេកទេសពេទ្យបានដោយមានប្រសិទ្ធភាពដើម្បីបន្ថយការចម្លងរីករាលដាលនៃជំងឺ។

ដូច្នេះ បើលោកអ្នកមានកូន ឬកុមារដែលមានបញ្ហាស្បែក សូមអញ្ជើញមកពិគ្រោះជាមួយគ្រូពេទ្យជំនាញសើស្បែកនៅមន្ទីរពេទ្យកាល់ម៉ែត ដែលផ្តល់ការប្រឹក្សា និងការព្យាបាលត្រឹមត្រូវតាមបច្ចេកវិជ្ជាពេទ្យប្រកបដោយប្រសិទ្ធភាព។

កត្តាប្រឈម នៃការធ្លាក់ឈាមក្រោយសម្រាល!
"Hémorragie du post-partum"

១) អ្វីទៅជាការធ្លាក់ឈាមក្រោយសម្រាល?

រាល់ការបាត់បង់ឈាមដែលមានបរិមាណចាប់ពី ៥00ml ឡើងទៅនោះគេហៅថាការធ្លាក់ឈាមក្រោយសម្រាល។ ហើយបើការបាត់បង់ឈាមចាប់ពី ១000ml នោះគេហៅថាការធ្លាក់ឈាមកម្រិតធ្ងន់ធ្ងរ។

ការធ្លាក់ឈាមក្រោយសម្រាលគេបែងចែកជា ២ប្រភេទ៖

- ការធ្លាក់ឈាមក្រោយសម្រាលភ្លាមៗ (Hémorragie du post-partum immédiate): រាល់ការបាត់បង់ឈាមដែលមានបរិមាណចាប់ពី ៥00ml ឡើងទៅក្នុងអំឡុងពេល ២៤ម៉ោងក្រោយសម្រាល។
- ការធ្លាក់ឈាមក្រោយសម្រាលអូសបន្លាយ (Hémorragie du post partum tardive):រាល់ការបាត់បង់ឈាមដែលមានបរិមាណចាប់ពី៥00mlក្នុងរយៈពេលលើសពី ២៤ម៉ោងរហូត ដល់ ៦សប្តាហ៍។

ចំណាំ៖ ចំពោះស្ត្រីដែលមានភាពស្លេកស្លាំងនៅពេលមានផ្ទៃពោះគ្រប់ខែ ទោះជាការបាត់បង់ឈាមតិចជាង ៥00mlក៏អាចប៉ះពាល់ដល់អាយុជីវិតផងដែរមិនចាំបាច់ដល់តែលើសពី ៥00ml ទេ។

២) មូលហេតុនៃការធ្លាក់ឈាមក្រោយសម្រាល?

- ស្បូនទន់ ឬខ្សោយនៅការកន្ត្រាក់រួមមកវិញក្រោយសម្រាល (Atonie utérine 70%)
- ការដាច់រហែកនៅតំបន់ទ្វារមាស តំបន់មាត់ស្បូន ឬតំបន់ប៉ែរីណេ (Déchirure des filières génitales 20%)
- ការនៅសល់សុក ឬកម្ទេចសុកនៅក្នុងស្បូន (Rétention placentaire ou débris placentaires 10%)
- វិបត្តិកំនកឈាម (Trouble de coagulation 9%)

៣) កត្តាប្រឈម (Facteur de risques) ៖

- កត្តាបណ្តាលមកពីស្បូនរីកធំក្នុងអំឡុងពេលមានផ្ទៃពោះ ដូចជាករណី:
  - កូនធ្លោស (Gros foetus)
  - កូនភ្លោះ (Grossesse multiple)
  - ទឹកភ្លោះច្រើន (Hydramnios)
- ស្ត្រីធ្លាប់សម្រាលកូនច្រើនដង (Multiparité)
- ស្ត្រីដែលធាត់ពេកពេលមានផ្ទៃពោះ (Obésité)
- ស្ត្រីដែលធ្លាប់មានប្រវត្តិដូចជា៖ ឈឺពោះយូរ, សម្រាលបុត្រលឿនពេក, ស្ត្រីធ្លាប់មានការធ្លាក់ឈាមក្រោយសម្រាល
- ស្ត្រីដែលមានសុកពាំងមាត់ស្បូន (Placenta prévia) មានដុំឈាមកកនៅពីក្រោយសុក (Hématome rétro-placentaire) មានដុំសាច់នៅនឹងស្បូន (Myome utérin)។
- ស្ត្រីដែលមានភាពស្លេកស្លាំងក្នុងពេលមានផ្ទៃពោះ (Anémie maternal)។
- កត្តាប្រឈមមកពីការប្រើប្រាស់ថ្នាំមួយចំនួន Inhibiteur calcique, Bêta-mimétique , Anticoagulants...
- កត្តាប្រឈមមកពីវិបត្តិកំណកឈាមពីកំណើត (Trouble de constitutionnel de l'Hémostase congénitale)

៤) ជំងឺវិបាកដែលស្ត្រីអាចជួប (Complications)៖

- វិបត្តិកំណកឈាមដែលធ្វើឲ្យមានការបាត់បង់ជីវិត
- វិបត្តិផ្លូវតម្រងនោម (ខូចតម្រងនោម)
- វិបត្តិគ្មានកូន

៥) ការព្យាបាល (Traitements)៖

- ការព្យាបាលដោយប្រើប្រាស់ថ្នាំជាមួយនឹងការសង្កត់សរសៃឈាមអាក់អក (Aorte)
- ការស្វែងរកនៅកន្លែងដែលរហែករួចដេរឡើងវិញ
- ការព្យាបាលដោយចងសរសៃឈាម (Ligature vasculaire) និងចងស្បូនផ្ចិបជាប់គ្នា (Plicature utérine)។
- ការព្យាបាលដោយកាត់ស្បូន (Hystérectomie)
- ការព្យាបាលដោយបាញ់ភ្ជិតសរសៃឈាមអាកទែរ (Embolisation artérielle)។

៦) អនុសាស្ត្ររបស់ក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យកាល់ម៉ែត៖

- ស្ត្រីគួរមកពិនិត្យផ្ទៃពោះឲ្យបានទៀងទាត់តាមការណាត់របស់គ្រូពេទ្យដើម្បីឲ្យគ្រូពេទ្យស្វែងរកនៅកត្តាប្រឈមមួយចំនួនដែលស្ត្រីមាននៅកំឡុងពេលមានផ្ទៃពោះ។
- ស្ត្រីគួរញ៉ាំជាតិដែកឲ្យបានតិចបំផុត ៩0គ្រាប់ ចំពោះស្ត្រីដែលគ្មានភាពស្លេកស្លាំងពីមុន។
- ស្ត្រីមិនត្រូវឲ្យឡើងទំងន់ខ្លួនខ្លាំងពេកទេនៅពេលមានផ្ទៃពោះរហូតដល់ពេលគ្រប់ខែ។ ជាធម្មតាស្ត្រីគួរតែឡើងទំងន់ត្រឹម ១២គីឡូក្រាម នៅពេលគ្រប់ខែ។
- ស្ត្រីគួរមកសម្រាលបុត្រនៅកន្លែងណាដែលមានគ្រប់ជំនាញនិងសំភារៈចំពោះស្ត្រីដែលគ្រូពេទ្យរកឃើញថាគាត់មានកត្តាប្រឈមនៅពេលមានផ្ទៃពោះ។

របៀបការពារទារកឈ្លក់ទឹកដោះ!

ការបំបៅដោះគឺជាមធ្យោបាយផ្តល់អាហារតែមួយគត់ចំពោះទារក។ទារកទើបនឹងកើតអាចប្រឈមនឹងការឈ្លក់ប្រសិនបើការបំបៅមិនបានត្រឹមត្រូវ។

១) អ្វីទៅជាការឈ្លក់ទឹកដោះ?
ជាការលេបចូលទឹកដោះដោយចៃដន្យទៅក្នុងសួត។ ការឈ្លក់នេះទៀតសោតអាចបង្កឲ្យមានផលប៉ះពាល់ដល់សុខភាពទារកយ៉ាងខ្លាំង។

២) កត្តាអ្វីខ្លះដែលធ្វើឲ្យទារកឈ្លក់?
ទារកដែលប្រឈមនឹងការឈ្លក់អាចជា៖
- ទារកដែលកើតមិនគ្រប់ខែ ឬទម្ងន់មិនគ្រប់
- ទារកដែលមានបញ្ហាបេះដូង
- ទារកដែលមានភាពមិនប្រក្រតីពីកំណើតដូចជាឆៃបមាត់ ឬក្រអូមមាត់
- ទារកដែលក្អែញក្អាញ់
- ក្រៅពីនេះក៏មានការរៀបចំស្ថានភាពទារកឲ្យបៅ ឬការបំបៅមិនបានត្រឹមត្រូវ

៣) តើមានផលវិបាកអ្វីខ្លះ ប្រសិនបើទារកឈ្លក់ទឹកដោះ?
- អាចបង្កឲ្យមានរលាកផ្លូវដង្ហើម ឬរលាកសាច់សួតពីស្រាលដល់ធ្ងន់ធ្ងរ រហូតដល់បាត់បង់ជីវិតក៏មាន
- ទារកអាចមានបញ្ហាកង្វះជាតិទឹក ឬអាហារូបត្ថម្ភ
- ទារកអាចនឹងមិនសូវឡើងទម្ងន់



៤) តើមានសញ្ញាអ្វីខ្លះ ដែលបញ្ជាក់ថាទារកមានឈ្លក់ទឹកដោះ?
ជាទូទៅរោគសញ្ញាស្តែងចេញទៅតាមភាពញឹកញាប់នៃការឈ្លក់និងបរិមាណឬប្រភេទទឹកដោះដែលបានឈ្លក់។
រោគសញ្ញាអាចមាន៖
- លែងចង់បៅ ឬងាកចេញ
- ប្តូរពណ៌សម្បុរពីក្រហម ទៅជាស្វាយ ឬខ្មៅ
- ពិបាកដកដង្ហើម ដង្ហក់ ឬឈប់ដកដង្ហើម
- ក្អក ពេលកំពុងបៅ រឺក្រោយបៅ
- ក្រៅពីនេះអាចមានជារលាកសួតពុំរ៉ៃ ឬញឹកញាប់

៥) តើធ្វើដូចម្តេចកុំឲ្យទារកឈ្លក់ទឹកដោះ?
ការឈ្លក់ដែលប្រឈមនឹងគ្រោះថ្នាក់គឺភាគច្រើនដោយការបំបៅទឹកដោះគោ។
- ត្រូវបំបៅទារកដោយដាក់មាត់ទារកឲ្យស៊ប់នឹងក្បាលដោះ។
-រៀបចំស្ថានភាពទារកឲ្យបានត្រឹមត្រូវដោយលើកទារកបញ្ជិតឲ្យបានប្រហែល ៣០ដឺក្រេពីផ្ទៃរាប រាល់ពេលបំបៅ។
-ក្រោយពេលបំបៅលើកទារកផ្អៅបលើខ្លួននិងស្មាដោយអង្អែលខ្នងតិចៗឲ្យបានយ៉ាងតិច៣០ទៅ៦០នាទី មុននឹងដាក់ឲ្យទារកគេងលើផ្ទៃរាបស្មើវិញ។
- ប្រសិនបើទារកក្អែញក្អាញ់ សូមព្យាយាមបំបៅទារកតិចៗ តែញយដង។

សូមអញ្ជើញមកពិគ្រោះជាមួយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យកាល់ម៉ែតប្រសិនបើកូនលោកអ្នកនៅតែមានអាការៈឈ្លក់ញឹកញាប់។សូមចងចាំថា"ទឹកដោះម្តាយគឺជាជម្រើសអាហារដ៏មានសុវត្ថិភាពតែមួយគត់ចំពោះទារកដែលទើបនឹងកើត"។

ជំងឺកន្ទុយថ្លែន!

ជំងឺកន្ទុយថ្លែនជាប្រភេទជំងឺដែលកើតមាននៅលើភ្នាសសនៃភ្នែកដោយមានការដុះឡើងនូវភ្នាសពណ៌ស មានរាងដូចស្លាបសត្វ ឬរាងជាត្រីកោណ និងមានសរសៃឈាមដុះមកជាមួយ។ភ្នាសកន្ទុយថ្លែនអាចមានការលូតលាស់ពីកម្រិតតូចស្តើងទៅកាន់កម្រិតធំក្រាស់ដែលភ្នាសនេះអាចដុះគ្របលើកញ្ចក់ភ្នែកដោយចាប់ផ្តើមលូនបន្តិចម្តងៗពីគែមនៃកញ្ចក់ភ្នែកទៅកាន់ផ្នែកកណ្តាលនៃកញ្ចក់ភ្នែករហូតដល់បាំងកូនក្រមុំប្រសិនបើមិនបានធ្វើការការពារនិងព្យាបាលឲ្យបានត្រឹមត្រូវ។

ក) រោគសញ្ញានៃជំងឺកន្ទុយថ្លែន៖

ជាទូទៅជំងឺកន្ទុយថ្លែនមិនបង្កឲ្យមានការឈឺចាប់ខ្លាំងនោះទេ ប៉ុន្តែវាអាចធ្វើឲ្យអ្នកជំងឺមានអាការៈមិនស្រួលដូចខាងក្រោម៖

- ផ្សាភ្នែក ក្តៅក្នុងភ្នែក និងរកាំភ្នែក
- ក្រហមភ្នែកនៅត្រង់ភ្នាសកន្ទុយថ្លែនដែលមានរលាក
-ស្រវាំងភ្នែកក្នុងករណីភ្នាសកន្ទុយថ្លែនដុះធំក្រាស់មកលើកញ្ចក់ភ្នែកឬដុះបាំងកូនក្រមុំ។

ខ) កត្តាប្រឈមដែលអាចបង្កឲ្យកើតជំងឺកន្ទុយថ្លែន៖

កត្តាដែលអាចបង្ក និងជំរុញ ឲ្យភ្នាសកន្ទុយថ្លែនដុះឡើង និងលូតលាស់កាន់តែធំគឺ:

- ការប៉ះជាមួយកាំរស្មីព្រះអាទិត្យខ្លាំង ដែលជះមកលើភ្នែកជាញឹកញាប់ "ការស្រាវជ្រាវបានរកឃើញថា អត្រានៃអ្នកកើតជំងឺកន្ទុយថ្លែនមានច្រើននៅប្រទេសដែលទទួលកាំរស្មីព្រះអាទិត្យ (កាំរស្មី UV) កម្រិតខ្ពស់ និងនៅលើប្រជាជនដែលធ្វើការក្រោមពន្លឺព្រះអាទិត្យខ្លាំង"
- ភាពកខ្វក់នៃបរិស្ថាន និងបរិយាកាសដែលមានធូលី និងខ្យល់ខ្លាំង
- អាយុកាន់តែច្រើន កាន់តែធ្វើឲ្យអ្នកប្រឈមខ្ពស់នឹងការកើតជំងឺកន្ទុយថ្លែន
- កត្តាខាងលើរួមបញ្ចូលគ្នាបង្កឲ្យអ្នកជំងឺប្រឈមនឹងការកើតជំងឺកន្ទុយថ្លែនកាន់តែខ្ពស់។

គ) ការការពារជំងឺកន្ទុយថ្លែន៖

-ការពាក់វ៉ែនតាការពារភ្នែកពីកាំរស្មីព្រះអាទិត្យនិងធូលីជាវិធីដ៏ងាយស្រួលនិងល្អបំផុតក្នុងការការពារអ្នកមិនឲ្យកើតមាននូវជំងឺកន្ទុយថ្លែន។
- ការពិនិត្យ និងពិគ្រោះយោបល់ជាមួយគ្រូពេទ្យឯកទេស អាចជួយអ្នកក្នុងការការពារ និងកាត់បន្ថយការដុះលូតលាស់លឿននៃភ្នាសកន្ទុយថ្លែន។

ឃ) រោគវិនិច្ឆ័យនៃជំងឺកន្ទុយថ្លែន៖

-ការពិនិត្យផ្ទាល់ទៅលើលក្ខណៈសណ្ឋាននិងរូបរាងនៃភ្នាសកន្ទុយថ្លែនអាចឲ្យគ្រូពេទ្យរកឃើញរោគវិនិច្ឆ័យនៃជំងឺកន្ទុយថ្លែនបានដោយជាក់លាក់។
- ការរកឃើញរោគវិនិច្ឆ័យឲ្យបានត្រឹមត្រូវ រួមជាមួយនិងការប្រឹក្សាយោបល់ជាមួយគ្រូពេទ្យឯកទេសផ្នែកចក្ខុសាស្ត្រ ឬចក្ខុមាត្រការី ជាកត្តាចម្បងក្នុងការការពារនិងព្យាបាលជំងឺកន្ទុយថ្លែនប្រកបដោយប្រសិទ្ធភាព។

ង) ការព្យាបាលជំងឺកន្ទុយថ្លែន

-ការព្យាបាលជំងឺកន្ទុយថ្លែនមានលក្ខណៈខុសៗគ្នាទៅតាមអាការៈនៃជំងឺ និងកម្រិតនៃភ្នាសកន្ទុយថ្លែន។
-ជំងឺកន្ទុយថ្លែនមិនអាចធ្វើការព្យាបាលជាសះស្បើយតាមរយៈការបន្តក់ថ្នាំភ្នែកឡើយ។
-ការវះកាត់ព្យាបាលមិនបានត្រឹមត្រូវល្អអាចធ្វើឲ្យអត្រានៃការដុះភ្នាសកន្ទុយថ្លែនឡើងមកវិញមានកាន់តែខ្ពស់។



សូមមកទទួលយកការពិនិត្យ ណែនាំ ដើម្បីការពារ និងព្យាបាលជំងឺកន្ទុយថ្លែនពីក្រុមគ្រូពេទ្យឯកទេសចក្ខុសាស្ត្រនៃមន្ទីរពេទ្យកាល់ម៉ែត ដើម្បីសុខភាព និងសោភ័ណភាពភ្នែករបស់អ្នក។

សំណួរចម្លើយ Quiz
ទាក់ទងនឹងសុខភាព

Q1. តើអ្នកជំងឺទឹកនោមផ្អែមអាចធ្វើការបរិច្ចាគឈាមបានដែលឬទេ?

១. មិនអាចបរិច្ចាគឈាមបានទេពីព្រោះឈាមមានជាតិផ្អែមអាចមានផលប៉ះពាល់។

២. អាចបរិច្ចាគឈាមបានចំពោះអ្នកជំងឺទឹកនោមផ្អែមស្ថិតក្នុងការគ្រប់គ្រងល្អប្រសើរ។

Q2.ខាងក្រោមនេះ តើមួយណាជាមូលហេតុ ឬកត្តាដែលបណ្តាលឲ្យកូនគម្រាមកើតមិនគ្រប់ខែ?

១. ការធ្វើការងារស្រាលៗ

២. ដើរ និងឡើងជណ្តើរញឹកញាប់

៣. ពិនិត្យ តាមដានផ្ទៃពោះញឹកញាប់

Q3. រោគសញ្ញាដែលតែងតែជួបញឹកញាប់ចំពោះអ្នកជំងឺដែលមានបញ្ហាច្រមុះដូចជា: កណ្តាស់ ហៀរសំបោរថ្ពាល់ រមាស់ច្រមុះ និងតឹងច្រមុះសងខាង តើសញ្ញាទាំងអស់នេះមាននៅក្នុងជំងឺអ្វី?

១. រៀចឆ្នឹងច្រមុះ

២. ដុះសាច់ច្រមុះ

៣. អាល់ឡែកស៊ីច្រមុះ

៤. ផ្តាសាយ

Q4.តើការគេងផ្អៀងទៅខាងណាដែលមានផលល្អប្រសើរសម្រាប់ស្ត្រីមានផ្ទៃពោះ?

១. ស្ត្រីមានផ្ទៃពោះគួរគេងផ្អៀងមកខាងស្តាំ

២. ស្ត្រីមានផ្ទៃពោះគួរគេងផ្អៀងមកខាងឆ្វេង

ឧបត្ថម្ភដោយ

លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧

អ៊ីម៉ែល: hospital@calmette.gov.kh, វែបសាយ: www.calmette.gov.kh

ហ្វេសប៊ុក: www.facebook.com/calmette.gov.kh

មន្ទីរពេទ្យកាល់ម៉ែតជាមន្ទីរពេទ្យរដ្ឋបាលក្រោមឱវាទក្រសួងសុខាភិបាល
មន្ទីរពេទ្យកាល់ម៉ែតជាមន្ទីរពេទ្យរដ្ឋបាលក្រោមឱវាទក្រសួងសុខាភិបាល
មន្ទីរពេទ្យកាល់ម៉ែតជាមន្ទីរពេទ្យរដ្ឋបាលក្រោមឱវាទក្រសួងសុខាភិបាល